ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ
Ministry of Agriculture,
Forestry and Fisheries

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

នាយកដ្ឋាន
ផលិតកម្ម និងបសុពេទ្យបាល
លេខ ៨៥២
ថ្ងៃទី 11.07.01
ម៉ោង 3h30

លេខ: ២៤៤ ប្រក.កសក

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការជ្រើសរើស និង ការបណ្តុះបណ្តាល ភ្នាក់ងារសុខភាពសត្វភូមិ

---

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ មិនា ឆ្នាំ ២០០១ ស្តីពីការបង្កើត និង គ្រប់គ្រង ភ្នាក់ងារសុខភាពសត្វភូមិ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សំរេច

ប្រការ ១ : ភ្នាក់ងារសុខភាពសត្វភូមិត្រូវបានជ្រើសរើស ក្នុងចំណោមពលរដ្ឋទាំងពីរភេទ នៅតាមមូលដ្ឋាន មកធ្វើការបណ្តុះបណ្តាល ដោយត្រូវមានលក្ខណៈសម្បត្តិ :-

- ចេះអាន ចេះសរសេរ ចេះគិតលេខ
- មានសុខភាពល្អ អាចបំពេញការងារបាន
- មានអាយុចាប់ពី ១៨ឆ្នាំឡើង
- មានសញ្ជាតិខ្មែរ
- មានរស់នៅផ្ទាល់ច្បាស់លាស់ក្នុងមូលដ្ឋាន និងស្ម័គ្រចិត្តបំរើការងារផលិតកម្មនិងបសុព្យាបាលនៅមូលដ្ឋាននោះ

**ប្រការ ២** : ការបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិត្រូវរៀបចំឡើង ដោយការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត-ក្រុងតាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត-ក្រុងនោះ ហើយនឹងមានការឯកភាពពី នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

**ប្រការ ៣** : កម្មវិធី និង ឯកសារបណ្តុះបណ្តាល ផ្នែកទ្រឹស្តី និងអនុវត្តជាក់ស្តែង ត្រូវរៀបចំជានិយាមមួយ ដោយ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

**ប្រការ ៤** : ភ្នាក់ងារសុខភាពសត្វភូមិ ដែលបានបណ្តុះបណ្តាលតាមកម្មវិធី និង ឯកសារនិយាមនេះ ត្រូវបានទទួល វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា នៅពេលបញ្ចប់វគ្គសិក្សា ដែលមានការទទួលស្គាល់ពីនាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល ។

**ប្រការ ៥** : ពលរដ្ឋទាំងឡាយណា ដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសផលិតកម្ម និង បសុព្យាបាលរួចហើយដោយអង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ ឬអង្គការអន្តរជាតិនានា ត្រូវដាក់ពាក្យស្នើសុំតាមរយៈ ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុង មកនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដើម្បីធ្វើការត្រួតពិនិត្យ និង វាយតម្លៃក្នុងការចេញវិញ្ញាបនប័ត្រភ្នាក់ងារសុខភាពសត្វភូមិ ។

**ប្រការ ៦** : ពលរដ្ឋទាំងឡាយ ដែលមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ភ្នាក់ងារសុខភាពសត្វភូមិដែលទទួលស្គាល់ ដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលអាចដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើសេវាកម្មផលិតកម្ម និង បសុព្យាបាល ។

**ប្រការ ៧** : អគ្គនាយក អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធិភាព តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩** : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៦ ខែ 7 ឆ្នាំ ២០០១

រដ្ឋមន្ត្រី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

**ដើម្បីជូនជ្រាប**

- ដូចប្រការ ៧

**ដើម្បីអនុវត្ត**

- ឯកសារ-កាលប្បវត្តិ